កុមាររៀន កុមារចេះ

ក ១ ២៣

# ប្លេះប្លោះទៅបេះផ្កា



**កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា**


រឿង ៖ **ប្លេះប្លោះទៅបេះផ្កា**
និពន្ធដោយ ៖ **អ្នកគ្រូ ហ៊ុន ធីតា**
កែសម្រួលដោយ ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**
វិចិត្ររូបភាពដោយ ៖ **លោក ឃួម កុសល**


សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

www.LetsReadAsia.org

ប្លេះប្លោះចូលចិត្តប្រឡែងលេងជាមួយ
មិត្តភក្តិ។







ប្លេះប្លោះក៏ប្រឹងប្រែង
រៀន និងជួយធ្វើ
ការងារពុកម៉ែដែរ។



ថ្ងៃចូលឆ្នាំប្រពៃណីជាតិខ្មែរជិតមកដល់ហើយ។ ប្លេះប្លោះគិតថា «យើងមានគ្រប់អស់ហើយ នៅខ្វះតែផ្កាទេ»។

បើទិញផ្កានៅពេលនេះ វាប្រាកដជាថ្លៃណាស់។ ខ្ញុំទៅបេះផ្កាដោយខ្លួនឯងវិញប្រសើរជាង។



ប្លេះប្លោះក៏សុំពុកម៉ែទៅបេះផ្កា។
«ពុកម៉ែ! បើយើងទិញផ្កានៅពេលនេះ វា
ប្រាកដជាថ្លៃណាស់។ តើកូនសុំទៅបេះផ្កា
ដោយខ្លួនឯងបានដែរទេ?»



ពុកប្លេះប្លោះ ៖ «តើកូនទៅបេះផ្កាដោយខ្លួនឯងឬ?» ។ ម៉ែប្លេះប្លោះ ៖ «ពុកម៉ែជឿជាក់ថា កូនមិនធ្វេសប្រហែសទេណា»។



កំពុងតែដើរ ប្លេះប្លោះឃើញ
សត្វមួយននៀលនៅលើដី។



ប្លេះប្លោះយកដៃប្រុងចាប់ត្រី តែ...
ត្រីក្រាញ់ ៖ «បងប្រុស! កុំចាប់ខ្ញុំអី។
ខ្ញុំក៏ចង់រស់ដូចបងដែរ»។




តើប្អូនត្រីខំប្រឹងនៀលទៅណា?
ខ្ញុំចេញពីថ្លុកក្បែរនោះ
ដោយសារខ្ញុំចង់ទៅរកទឹក
បឹងដែលមានទឹកជ្រៅ។


ខ្ញុំធ្លាប់ឃើញមានបឹងធំ
មួយនៅក្បែរៗនេះ។
ខ្ញុំនឹងយកឯងទៅទីនោះ។
អរគុណបងប្រុស!

ប្លេះប្លោះខំប្រឹងបោលប្លោតៗ។
ប្លេះប្លោះលោតប្លោតចុះ ប្លោត
ឡើងយ៉ាងប្រញាប់ប្រញាល់។











ប្លេះប្លោះក៏ឈប់នៅ
ក្រោមដើមផ្ទៀវ។

ប្លេះប្លោះប្រាប់ត្រីក្រាញ់ ៖ «យើងមកដល់បឹងហើយ។ បឹងនេះ ថែមទាំងមានផ្កាឈូកទៀតផង»។





ត្រីក្រាញ់ ៖ «ខ្ញុំសូមអរគុណបងប្រុស។
ទីនេះពិតជាខុសប្លែកពីទឹកថ្លុក ដែលខ្ញុំធ្លាប់
រស់នៅមែន»។ ប្លេះប្លោះ ៖ «មិនអីទេប្អូនត្រី!
យើងត្រូវចេះជួយគ្នាទៅវិញទៅមក»។




ប្លេះប្លោះក៏យកឈើវែងមួយ ថ្ពក់បេះផ្កាឈូក។

រីឯត្រីក្រាញ់ក៏ជួយបេះផ្កាឈូកឱ្យប្លេះប្លោះ
ដែរ។





ប្លេះប្លោះកាន់ផ្កាឈូកដើរត្រឡប់ទៅភូមិវិញទាំងទឹកមុខរីករាយ។ ប្លេះប្លោះនិយាយតែឯង ៖ «ផ្កានេះទុកថ្វាយទេវតា។ ផ្កានេះទុកផ្ញើម៉ែ ហើយផ្កានេះទុកផ្ញើពុក»។

ប្លេះប្លោះរៀបរាប់ប្រាប់ពុកម៉ែថា
«ថ្ងៃនេះ ខ្ញុំបានបេះផ្កាឈូកទុកថ្វាយ
ទេវតា។ ខ្ញុំថែមទាំងបានជួយយក
អាសាត្រីក្រាញ់ទៀតផង»។





ប្លេះប្លោះនិងពុកម៉ែក៏នាំគ្នាបត់ផ្កាឈូក
ដោយផ្ចិតផ្ចង់ ទុកថ្វាយទេវតាឆ្នាំថ្មី។

# ពន្យល់ពាក្យ

១. **ធ្វេសប្រហែស** : មិនសូវប្រយ័ត្ន

២. **អត់ធ្មត់** : ខំទប់ចិត្ត

៣. **ផ្ចិតផ្ចង់** : ធ្វើដោយផ្ចង់អស់ពីចិត្ត អស់ពីចំណង់

៤. **ថ្វាយ** : ឱ្យ ប្រគល់ បូជា (សម្រាប់ប្រើជាមួយព្រះ និងព្រះមហាក្សត្រ)

៥. **ប្រាកដ** : ពិត ជាក់ច្បាស់



# សំណួរ

១. តើប្លេះប្លោះចង់ទៅណា?

២. តើប្លេះប្លោះបានជួបនរណានៅក្បែរថ្លុក?

៣. ហេតុអ្វីបានជាប្លេះប្លោះជួយយកអាសាត្រីក្រាញ់?

៤. ចុះកូនវិញ តើកូនធ្លាប់ជួយយកអាសាគេដែរឬទេ?
តើកូនជួយគេដោយរបៀបណា?













IPEA, Kg.Chhnang, 789 copies, SSK, Oct. 2022

បន្ទាប់ពីរៀនចប់មេរៀនទី១២ វំពុក **«ព្យញ្ជនៈផ្ញើជើង ផ្ក ផ្ង ផ្ន ផ្ញ»** នៃសៀវភៅថ្នាក់ទី២ សិស្សនឹងអាចអានសៀវភៅរឿងនេះបានដោយខ្លួនឯង ដោយពុំចាំបាច់មានអ្នកដទៃជួយឡើយ។

ទោះជាយ៉ាងណា សិស្សថ្នាក់ទី១ ក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើលនិងរៀបរាប់អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះ ហើយអានពាក្យនិងតួអក្សរដែលពួកគេស្គាល់។

សូមចងចាំថា នៅពេលសិស្សចាប់ផ្តើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែប្រសើរសម្រាប់ពួកគេ!



កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង
នៃក្រសួងអប់រំ យុវជន និងកីឡា

9 789924 560388

បោះពុម្ពឆ្នាំ២០២២